**LASED**

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច
និងការអភិវឌ្ឍសេដ្ឋកិច្ច

# ដីខ្ញុំមានសុវត្ថិភាពហើយ

## សុវត្ថិភាពដីធ្លីកើតមានតាមរយៈការចុះបញ្ជីដីធ្លី




- ប័ណ្ណនេះជាភ័ស្តុតាងបញ្ជាក់ពីកម្មសិទ្ធស្របច្បាប់របស់អ្នក
- ប័ណ្ណនេះត្រូវបានការពារដោយច្បាប់ និងធានាដោយរដ្ឋ

## ខ្ញុំទទួលបានដីលំនៅឋានហើយ តើខ្ញុំត្រូវធ្វើដូចម្តេចខ្លះ?

- អ្នកត្រូវសាងសង់ចំណែកណាមួយនៃលំនៅ ឋានក្នុងអំឡុងពេល៣ខែបន្ទាប់ពីទទួលបានដីនេះ។
- អ្នក ឬសមាជិកគ្រួសាររបស់អ្នកត្រូវរស់នៅពិតប្រាកដលើដីលំនៅឋាននេះ ឲ្យបានលើសពី៦ខែ ក្នុង១ឆ្នាំ។



ក្រសួងរៀបចំដែនដី នគរូបនីយកម្ម

ក្រសួងមហាផ្ទៃ


ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
អាសយដ្ឋាន: អគារលេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ,
Email: lased@ezecom.com.kh



បោះពុម្ពនៅរាជធានីភ្នំពេញ ខែតុលា ឆ្នាំ ២០១២ ចំនួន២៥០សន្លឹក
ដោយគម្រោង LASED/GSSLC


## ខ្ញុំទទួលបានដីកសិកម្មហើយ តើខ្ញុំត្រូវធ្វើដូចម្តេចខ្លះ?

អ្នកត្រូវដាំដុះលើដីនេះក្នុងរយៈពេល១២ខែ បន្ទាប់ពីទទួលបានដី និងបន្តប្រើប្រាស់ដីនេះជារៀងរហូត។







## តើអ្នកដទៃអាចរំលោភយកដីខ្ញុំបានដែរឬទេ?

អ្នកដទៃមិនអាចរំលោភយកដីរបស់អ្នកបានទេ។ ប៉ុន្តែបើអ្នកមិនបានបំពេញតាមលក្ខខណ្ឌសម្បទានដីសង្គមកិច្ចទេ រដ្ឋមានសិទ្ធិដកហូតដីនេះមកវិញ។

## តើខ្ញុំមានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិដីនេះដែរឬទេ?

អ្នកមានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិដីនេះបានបន្ទាប់ពីអ្នកបានរស់នៅ និងដាំដុះលើដីនេះរយៈពេល៥ឆ្នាំ។

## តើខ្ញុំត្រូវធ្វើដូចម្តេចដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិកាន់កាប់ដីនេះ?

ក្រោយពេលរស់នៅនិងធ្វើកសិកម្មជាលក្ខណៈគ្រួសារបានរយៈពេល៥ឆ្នាំលើដីដែលបានផ្តល់ឲ្យនោះ មេគ្រួសារអាចដាក់ពាក្យស្នើសុំកម្មសិទ្ធដីធ្លីនេះទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី តាមរយៈអាជ្ញាធរមូលដ្ឋាន ឃុំ ស្រុក ដែលខ្លួនរស់នៅ។





## តើខ្ញុំអាចលក់ ដោះដូរ ជួល បញ្ចាំ ឬផ្ទេរដីនេះបានទេ?

អ្នកមិនអាចលក់ ដោះដូរ ជួល បញ្ចាំ ឬផ្ទេរដីនេះទៅអ្នកដទៃបានទេក្នុងអំឡុងពេល៥ឆ្នាំដំបូង។ ប៉ុន្តែប្រសិនបើម្ចាស់ដីស្លាប់ សមាជិកក្រុមគ្រួសារអាចបន្តប្រើប្រាស់ដីនេះបាន។


**គាំទ្រដោយ**

THE WORLD BANK

WATHNAKPHEAP

COOPERATION KINGDOM OF CAMBODIA – FEDERAL REPUBLIC OF GERMANY

giz

CONSULT GOPA

គាំទ្រដោយ ក្រសួងអភិវឌ្ឍន៍ និង កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច នៃសហព័ន្ធអាល្លឺម៉ង់ (BMZ)
តាមរយៈកិច្ចសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ GIZ
(Deutsche Gesellschaft für Internationale Zusammenarbeit GmbH)


សម្រាប់ព័ត៌មានបន្ថែមពីសម្បទានដីសង្គមកិច្ច និងគម្រោង LASED
សូមទំនាក់ទំនង:
- មេភូមិ ឬ មេឃុំ
- ការិយាល័យភូមិបាលស្រុក ឬមន្ទីររៀបចំដែនដីរាជធានី/ខេត្ត
- អគ្គលេខាធិការដ្ឋានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ (អគសសជ)

## តើខ្ញុំត្រូវមានឯកសារអ្វីខ្លះដើម្បីស្នើសុំធ្វើប័ណ្ណកម្មសិទ្ធិ?

**អ្នកត្រូវមាន៖**

១. បង្កាន់ដៃប្រគល់ដីសម្បទានសង្គមកិច្ច
២. កិច្ចសន្យាសម្បទានដីសង្គមកិច្ច
៣. សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ
៤. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្រកំណើត ឬសំបុត្រអាពាហ៍ពិពាហ៍។










## ខ្ញុំមានប័ណ្ណគ្រួសារក្រីក្រហើយ តើខ្ញុំអាចប្រើប្រាស់វាសម្រាប់អ្វីខ្លះ?

លោកអ្នកអាច: យកប័ណ្ណនេះទៅបង្ហាញនៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក ឬនៅស្ថាប័ណ្ណ និងអង្គការផ្សេងៗដែលមានការផ្តល់ជំនួយ ដល់អ្នកក្រីក្រ ដើម្បីឲ្យស្ថាប័ណ្ណ និងអង្គការទាំងនោះ សម្រេចចិត្តផ្តល់ ឬមិនផ្តល់សេវា ឬជំនួយដល់សមាជិកគ្រួសារលោកអ្នក។




